GMAC

Garment Manufacturers Association in Cambodia

# សេចក្តីប្រកាសព័ត៌មាន

ភ្នំពេញថ្ងៃទី១៧ខែតុលាឆ្នាំ២០១៧:

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា នៅថ្ងៃអង្គារនេះនឹងដាក់ញត្តិរបស់ខ្លួនទៅកាន់រដ្ឋាភិបាលអាមេរិក ដើម្បីស្នើសុំនូវប្រព័ន្ធអនុគ្រោះពន្ធ(GSP) សម្រាប់ផលិតផលស្បែកជើងដែលនាំចេញទៅទីផ្សារអាមេរិក។ ការដាក់ញត្តិនេះ គឺក្នុងពេលដែលរដ្ឋាភិបាលអាមេរិកត្រូវពិនិត្យឡើងវិញនូវកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធ(GSP) នូវត្រឹមបំណាច់ចុងឆ្នាំនេះ។

ការដាក់ស្នើសុំនេះ គឺធ្វើឡើងដោយមានការគាំទ្រពីសំណាក់ក្រសួងពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលនឹងផ្អែកលើភាពជោគជ័យក្នុងការសម្រេចបាននូវការអនុម័តពីព្រឹទ្ធសភា ចំពោះច្បាប់ពង្រីកបន្ថែមនៃប្រព័ន្ធអនុគ្រោះពន្ធឆ្នាំ២០១៥ HR ១២៩៥ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែមិថុនាឆ្នាំ ២០១៥ ដែលបានធ្វើឱ្យបន្ទាត់ពន្ធចំនួន២៨ផ្សេង នៃមុខទំនិញសម្រាប់ប្រើធ្វើដំណើរ ដែលស្ថិតនៅក្នុង លេខ HTS ៤២០២ មានសិទ្ធិទទួលបានការអនុគ្រោះពន្ធ ក្រោមក្របខ័ណ្ឌ GSP ។

បច្ចុប្បន្ននេះ ការទទួលបាន GSP របស់កម្ពុជាមិនរាប់បញ្ចូលផលិតផលសម្លៀកបំពាក់និងស្បែកជើងដែលជាផលិតផលនាំចេញដ៏សំខាន់របស់ប្រទេសកម្ពុជា។ រដ្ឋាភិបាលអាមេរិកកំពុងពិនិត្យមើលឡើងវិញនូវគោលនយោបាយGSPប្រចាំឆ្នាំរបស់ខ្លួន ហើយសមាគមកំពុងធ្វើការជាមួយក្រុមហ៊ុនច្បាប់មួយដែលមានការិយាល័យនៅទីក្រុងវ៉ាស៊ីនតោនដើម្បីជួយក្នុងការដាក់សំណើរបស់ខ្លួន ហើយប្រសិនបើទទួលបានជោគជ័យនោះ គឺវាពិតជាអាចជួយដល់សេដ្ឋកិច្ចកម្ពុជាបានយ៉ាងច្រើនសន្ធឹកសន្ធាប់ដូចជា ការបង្កើនការនាំចេញ ការទាក់ទាញការវិនិយោគថ្មីៗនិងការបង្កើតការងារថ្មីសម្រាប់ប្រជាជនកម្ពុជា រាប់សិបពាន់នាក់។

GMAC បាននឹងកំពុងធ្វើការនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនច្បាប់នោះដើម្បីទទួលបានជោគជ័យ។ បើយោងតាមបុគ្គលិកនៃគណៈកម្មាធិការផ្នែកច្បាប់ គណៈកម្មាធិការ House Ways and Means Committee and the Senate Finance Committee វានឹងមានកិច្ចប្រឹងប្រែងរួមគ្នាដើម្បីពិនិត្យជាថ្មីឡើងវិញលើកម្មវិធីGSPទាំងមូល មុនកាលផុតកំណត់នៃកម្មវិធីនេះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ វិស័យផលិតស្បែកជើង គឺនៅតែជាឧស្សាហកម្មសើបមួយនៅក្នុង គោលនយោបាយពាណិជ្ជកម្មអាមេរិក ដែលការនេះនឹងអាចរារាំងមិនឱ្យមានការបញ្ចូលប្រភេទស្បែកជើងមួយចំនួន ទៅក្នុងបញ្ជីសិទ្ធិទទួលបាន GSP ហើយចំនួនប្រាក់ចំណូលពន្ធដែលបាត់បង់ ក៏នឹងអាចកំណត់កំរិតដែនកំណត់នៃប្រភេទស្បែកជើង



Phnom Penh Special Economic Zone, Trapeang Kol Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org

ដែលអាចត្រូវបានបញ្ចូលក្នុងបញ្ជីផងដែរ។ ជាដំណោះស្រាយ វិធីសាស្ត្រ របស់GMAC គឺ ព្យាយាមដាក់បញ្ចូលក្រោមច្បាប់នេះនៅប្រភេទ ស្បែកជើងដែលជាអាទិភាពរបស់កម្ពុជា។

បច្ចុប្បន្ន GMAC មានរោងចក្រផលិតស្បែកជើងចំនួន៥៩ ដែលបាននាំចេញនូវផលិតផល ដែលមានទឹកប្រាក់ប្រមាណជា ៧០០លានដុល្លារកាលពីឆ្នាំមុន។

GMAC សង្ឃឹមចំពោះកិច្ចប្រឹងប្រែងរបស់ខ្លួន បើទោះបីជាការផ្តល់GSPនេះ មិនត្រូវបានធានាថានឹងកើតឡើងនៅមុនពេលផុតកំណត់នៅចុងឆ្នាំនេះ ដោយសារភាពមមាញឹកនៃការងាររបស់ព្រឹទ្ធសភាអាមេរិកលើច្បាប់កំណែទម្រង់ការថែទាំសុខភាពនិងកំណែទម្រង់ពន្ធ។

យូរឬឆាប់ GMAC មានទំនុកចិត្តយ៉ាងមុតមាំថាញត្តិនេះនឹងទទួលបានការឆ្លើយតបជាវិជ្ជមានពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ដោយពិចារណាលើការកែលម្អឥតឈប់ឈររបស់យើងនៅក្នុងលក្ខខណ្ឌការងារនៅកម្ពុជា ជាពិសេសភាពប្រសើរឡើងនៃប្រាក់ឈ្នួលដែលនាំទៅដល់ការកែលម្អបន្ថែមទៀតនៃសុខុមាលភាពរបស់កម្មករ។

តាមក្របខណ្ឌពេលវេលាគឺត្រូវមានការខិតខំប្រឹងប្រែងធ្វើការខ្លាំងនៅចន្លោះខែតុលានិងខែធ្នូ ឆ្នាំ២០១៧នេះដើម្បីឱ្យច្បាប់នេះត្រូវបានដាក់បញ្ចូលទៅដល់ព្រឹទ្ធសភាសហរដ្ឋអាមេរិក។ ប្រសិនបើកម្មវិធីGSPនេះមិនត្រូវបានផ្តល់ឲ្យនៅចុងឆ្នាំនេះ កិច្ចខិតខំប្រឹងប្រែងនេះនឹងត្រូវបន្តរហូតដល់ខែធ្នូ ឆ្នាំ២០១៨។

GARMENT MANUFACTURERS ASSOCIATION IN CAMBODIA